# គោលការណ៍ណែនាំសម្រាប់អនុវត្តដំណាំគម្របរបស់ដើមក្រចៅ (*Crotolaria juncea*) ស្រូវសាលី (*Fagopyrum esculentum*) ឬស្រូវអាវ៉ែន (*Avena sativa*)

គោលបំណង និងកម្មវត្ថុធ្វើប្រព្រឹត្តកម្មដំណាំគម្រប :

- បង្កើនគុណភាពដី (បង្កើនសារធាតុសរីរាង្គដី និងសកម្មភាពជីវសាស្ត្រ បង្កើនអត្តិភាពផូស្វ័រ បង្កើតប្រភព ឬអាសូតក្នុងវាលជិតផ្ទះ)
- កាត់បន្ថយការហូរច្រោះដី និងកករ ចូលទៅក្នុងស្ទឹងបឹងបួរដែលនៅក្បែរៗនោះ
- វិធានការណ៍ការពារដំណាំ ដើម្បីកំចាត់ពពួកស្មៅចង្រៃ និងជម្ងឺកើតពីដី
- ទាក់ទាញសត្វល្អិតមានប្រយោជន៍ (សត្រូវធម្មជាតិរបស់សត្វល្អិតចង្រៃ សត្វឃ្មុំ)
- កាត់បន្ថយថ្លៃចំណាយលើ (ជី ថ្នាំសម្លាប់កត្តាចង្រៃ ឥន្ធនៈ)

**ការរៀបចំទីតាំង :** រៀបចំវាលដោយដកពពួលស្មៅចង្រៃអោយអស់ សម្អាតដីអាចម៍បំណេះ ឬដោយវិធីផ្សេងៗទៀត សម្អាតតំបន់ដែលត្រូវដាំដំណាំគម្របដែលបានជ្រើសរើស ។ ថ្នាំកំចាត់ស្មៅ ដូចជា ផលិតផលគ្លីផូសាត អាចត្រូវបានប្រើប្រាស់ដើម្បីសម្អាតវាលដែលមានពពួកស្មៅចង្រៃមុនធ្វើការដាំដុះដំណាំគម្រប ។ មិនត្រូវដាំដំណាំគម្របក្នុងរយៈពេល ៧ ថ្ងៃ ក្រោយពីបាញ់ថ្នាំកំចាត់ស្មៅទេ បើមិនដូច្នេះទេ វាអាចបំផ្លាញ ឬធ្វើអោយងាប់ដល់គ្រាប់ពូជដែលទើបចេញពន្លក ។

**អត្រាសាបព្រោះ :** អត្រាគ្រាប់ក្រចៅ : ៤០ ផោន ក្នុងផ្ទៃដីមួយអេឃើ

អត្រាគ្រាប់ស្រូវសាលី : ៦០ ផោន ក្នុងផ្ទៃដីមួយអេឃើ

អត្រាគ្រាប់ស្រូវអាវ៉ែន : ៧០ ផោន ក្នុងផ្ទៃដីមួយអេឃើ

**ការសាបព្រោះគ្រាប់ :** សម្រាប់វាលតូចៗ ឬប្រសិនបើធ្វើដំណាំចន្លោះ គ្រាប់អាចព្រោះដោយដៃ ឬដោយប្រើម៉ាស៊ីនសាបព្រោះជី/គ្រាប់ដែលប្រើដោយដៃ ។ សម្រាប់វាលធំៗ ការបាចគ្រាប់ដោយគ្រឿងយន្ត (ដោយប្រើត្រាក់ទ័រដាក់ជី/ម៉ាស៊ីនបាចជី/គ្រាប់) និង/ឬការសាបព្រោះជាជួរត្រូវបានប្រើដោយមានការសន្សំសំចៃជាង ។

**ការរួមបញ្ចូលគ្នា :** វាជាការសំខាន់ដែលមានដីគ្រប់គ្រាន់សម្រាប់ការដោតគ្រាប់ពូជអោយផ្ទាល់ ដូច្នេះវាជាវិធីល្អបំផុតដើម្បីដាក់បញ្ចូលគ្រាប់បានឆាប់រហ័សបន្ទាប់ពីការបាច ។ ក្នុងវាល ឬជួរតូចៗ ការងារនេះអាចត្រូវបានធ្វើឡើងដោយប្រើប្រាស់រនាស់ដែលអូសដោយត្រាក់ទ័រកង់បួន (ត្រាក់ទ័រភ្ជួររាស់-ATV) ឬដោយរាស់ដីលើគ្រាប់ ។ នៅតាមវាលធំៗរនាស់ធុនស្រាលដែលរាស់បានជម្រៅមិនលើសពី ១ អ៊ីញ គប្បីត្រូវបានប្រើប្រាស់ ។

**ល័ក្ខខ័ណ្ឌតម្រូវពេលវេលា និងការស្រោចស្រព :** ប្រសិនបើគ្រាប់ពូជត្រូវបានដាំមុនរដូវវស្សា (ពាក់កណ្តាលខែតុលាដល់ពាក់កណ្តាលខែមេសា) មិនចំបាច់មានការស្រោចស្រពសម្រាប់ដំណាំគម្របខាងលើទេ ។ នៅខែក្នុងរដូវក្តៅស្ងួត គឺចំបាច់ត្រូវមានការស្រោចស្រព ។ ចំណាំ : នៅពេលដែលក្រចៅត្រូវបានដាំរវាងខែកញ្ញា និងខែធ្នូ វានឹងឆាប់ចេញផ្កា (ជាទូទៅក្នុងរយៈពេល ៦ សប្តាហ៍នៃការដាំ) ។ សម្រាប់ផលិតកម្មគ្រាប់ រយៈពេលនេះត្រូវការជាចំបាច់ ។ ជាងនេះទៅទៀត រុក្ខជាតិក្រចៅមានរយៈពេលខ្លីជាង អំឡុងពេលខែកញ្ញា ដល់ខែធ្នូ ដោយសារការឆ្លើយតបចំពោះការចេញផ្កា ។ ក្រចៅដែលដាំពីខែមករា ដល់ខែសីហា នឹងមានកម្ពស់ (៥ ហ្វ៊ីត ឡើងទៅ) ដែលបង្កើនលទ្ធភាពប្រើប្រាស់របស់ជារបាំងទប់ខ្យល់ ។ ស្រូវសាឡី និងស្រូវអាវ៉ែន ជាទូទៅ មិនទទួលរងឥទ្ធិពលដោយសារពេលវេលានៃការដាំក្នុងឆ្នាំនោះទេ ។

**ការដុះពន្លក និងការដុះចេញ :** រយៈពេលដើម្បីដុះចេញគឺប្រហែល ៧ ទៅ ១០ ថ្ងៃ សម្រាប់ប្រភេទទាំងបីនៃដំណាំគម្រប បន្ទាប់ពីមានភ្លៀងដំបូងលើសពី 0,៥ អ៊ីញ ។ ក្រចៅនឹងដុះចេញពន្លកក្នុងរយៈពេល ២៤ ម៉ោង ។ ស្រូវសាឡី និងស្រូវអាវ៉ែន នឹងដុះចេញពន្លកក្នុងរយៈពេល ៧២ ម៉ោង បន្ទាប់ពីទទួលបានសំណើម ។

**ការគ្រប់គ្រង :** ជាទូទៅ មិនចាំបាច់ត្រូវមានការគ្រប់គ្រងច្រើនទេ ។ នៅពេលដែលដំណាំត្រូវបានដាំ ហើយទទួលបាន សំណើម វិធីសាស្រ្តល្អបំផុតគឺទុកដំណាំគម្របចោល ។ មិនចំបាច់ដាក់ជី មិនត្រូវការស្រោចស្រព និងមិនបាច់ប្រឹងប្រែងគ្រប់គ្រងកន្លាចង្រៃទេ ។ បន្ថយការគ្រប់គ្រងលើដំណាំគម្របអោយនៅកម្រិតទាបបំផុត គឺមានន័ថាកាត់បន្ថយថ្លៃចំណាយដែលពាក់ព័ន្ធនឹងការអនុវត្តអោយនៅកម្រិតទាបបំផុត ដូច្នេះធ្វើអោយវាកាន់តែមានការទាក់ទាញថែមទៀតដល់អ្នកដាំ ។



គម្របស្រូវសាឡី



គ្រាប់ស្រូវសាឡី



គម្របស្រូវអូក



គ្រាប់ស្រូវអូក



ក្រចៅនៅចន្លោះជួរដំណាំល្ហុង



គ្រាប់ក្រចៅ